# គោលការណ៍ណែនាំបច្ចេកទេសស្តីពី ការអនុវត្តកសិកម្មវៃឆ្លាតខាងអាកាសធាតុ សម្រាប់កសិករខ្នាតតូច

២០២៥



OXFAM
អង្គការអុកស្វាមកម្ពុជា

សាកលវិទ្យាល័យភូមិន្ទកសិកម្ម

គោលការណ៍ណែនាំបច្ចេកទេស ស្ដីពីការអនុវត្តកសិកម្មវៃឆ្លាតខាងអាកាសធាតុសម្រាប់កសិករខ្នាតតូច ត្រូវបានចងក្រងឡើងក្រោមកិច្ចសហការរវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងអង្គការដៃគូរពាក់ព័ន្ធ តាមរយៈគម្រោងពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុទន្លេមេគង្គ (SCR) ក្រោមការគាំទ្រថវិកាដោយអង្គការអុកស្វាមកម្ពុជា (Oxfam in Cambodia)។



# មាតិកា

១. សេចក្តីផ្តើម ........ ១

២. គោលបំណងនៃគោលការណ៍ណែនាំ ........ ២

៣. គោលគំនិតនៃ CSA ........ ២

៣.១. និយមន័យ ........ ២

៣.២. ក្រុមគោលដៅអនុវត្ត CSA និងវិសាលភាព ........ ៣

៤. សារៈប្រយោជន៍នៃការអនុវត្ត CSA ........ ៣

៥. បច្ចេកវិទ្យា និងការអនុវត្ត CSA ........ ៣

៦. តួនាទី និងអភិក្រមសម្រាប់ការពង្រីកការអនុវត្ត CSA ........ ៦

៦.១. តួនាទីរបស់ស្ថាប័ន/អ្នកពាក់ព័ន្ធក្នុងការអនុវត្ត និងពង្រីកការអនុវត្ត CSA ........ ៦

៦.២. អភិក្រមក្នុងការអនុវត្ត និងពង្រីកការអនុវត្ត CSA ........ ៩

៦.៣. ការធ្វើបង្ហាញ (Demonstration) ដើម្បីពង្រីកការអនុវត្ត CSA ........ ១០

៧. គោលការណ៍សម្រាប់លើកកម្ពស់ និងអនុវត្ត CSA ........ ១៤

៨. តម្រូវការកសាងសមត្ថភាព (គ្រប់កម្រិត - ជាតិ មូលដ្ឋាន និងកសិករ) ........ ១៧

ឯកសារយោង ........ ១៩

## ១. សេចក្ដីផ្ដើម

ការប្រែប្រួលអាកាសធាតុ និងអសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ បាននឹងកំពុងបង្កបញ្ហាប្រឈមចំពោះការអភិវឌ្ឍន៍ដ៏ធំបំផុតរបស់មនុស្សជាតិ។ ដូច្នេះ ប្រព័ន្ធកសិកម្មដែលមាននិរន្តរភាព ជាតម្រូវការជាចាំបាច់ចំពោះមុខ ដើម្បីមិនត្រឹមតែអាចព្យាបាលភពផែនដីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាបាននូវសន្តិសុខស្បៀងសម្រាប់មនុស្សទាំងអស់គ្នាផងដែរ។ សព្វថ្ងៃនេះ ប្រព័ន្ធកសិកម្មសកលបានបញ្ចេញមួយភាគបីនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ទាំងអស់ទៅក្នុងបរិយាកាស។ តម្រូវការស្បៀងអាហារជាសកល ត្រូវបានគេប៉ាន់ប្រមាណថា នឹងបន្តកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីចិញ្ចឹមប្រជាជនពិភពលោក ដែលត្រូវបានគេព្យាករណ៍ថានឹងបន្តកើនឡើងរហូតដល់ចំនួន ៩,៧ពាន់លាននាក់នៅត្រឹមឆ្នាំ២០៥០។ ការកើនឡើងនៃផលិតកម្មស្បៀងបានផ្សារភ្ជាប់ទៅនឹងការពង្រីកវិស័យកសិកម្ម និងការប្រើប្រាស់ដីនិងការប្រើប្រាស់ធនធានដែលគ្មាននិរន្តរភាព។ កត្តាទាំងនេះ បាននឹងកំពុងបង្កើតក្ដីកង្វល់ជាសាកល ជាពិសេសការនាំទៅរកការកើនឡើងនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស (World Bank, 2024)។

បច្ចុប្បន្ននេះ នៅប្រទេសកម្ពុជា ការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការណែនាំបច្ចេកវិទ្យាសមស្របដើម្បីបង្កើនផលិតកម្មកសិកម្មរបស់កសិករខ្នាតតូច គឺនៅមិនទាន់គ្រប់គ្រាន់ដើម្បីជួយដល់កសិករ ក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅឡើយ។ ប្រទេសនេះ ត្រូវបានចាត់ទុកថាជាប្រទេសមួយក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដូចជា សត្វល្អិតបំផ្លាញ ទឹកជំនន់ គ្រោះរាំងស្ងួត និងព្រឹត្តការណ៍អាកាសធាតុខុសប្រក្រតីជាដើម។ ការសម្របខ្លួន និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាកត្តាចាំបាច់ចំពោះមុខសម្រាប់កសិករខ្នាតតូច ដែលការចិញ្ចឹមជីវិតរបស់ពួកគេអាស្រ័យលើការធ្វើកសិកម្ម (SNV, 2024)។

ការអនុវត្តកសិកម្មវៃឆ្លាតខាងអាកាធាតុ (Climate-Smart Agriculture) ឬហៅកាត់ថា "CSA" គឺជាជម្រើសបន្សាំដ៏មានប្រសិទ្ធភាពសមស្របមួយដើម្បីលើកកម្ពស់ផលិតភាព បង្កើនប្រាក់ចំណូល ពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស សម្រាប់កសិករខ្នាតតូចនៅក្នុងប្រទេសកម្ពុជា។ ការអនុវត្ត CSA រួមបញ្ចូលនូវការអនុវត្តបច្ចេកវិទ្យាសមស្រប ដែលមានភាពបត់បែនជាច្រើន និងដែលអាចសម្របទៅនឹងលក្ខខណ្ឌគ្រប់បរិស្ថានជាក់លាក់ និងបរិបទសេដ្ឋកិច្ចសង្គមរបស់កសិករ។

ដើម្បីបង្កភាពងាយសម្រួលដល់កសិករ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងសហគមន៍មូលដ្ឋាន សាកលវិទ្យាល័យភូមិន្ទកសិកម្ម តាមរយៈគម្រោងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុទន្លេមេគង្គ (SCR) ដែលគាំទ្រថវិកាដោយអង្គការអុកស្វាមកម្ពុជា បានចងក្រងគោលការណ៍ណែនាំបច្ចេកទេសនេះឡើងដើម្បីជាឯកសារជំនួយស្មារតី និងជាត្រីវិស័យតម្រង់ទិសប្រព័ន្ធកសិកម្ម គាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងធានាឱ្យបាននូវសន្តិសុខស្បៀងនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុសម្រាប់កសិករខ្នាតតូចនៅកម្ពុជា។ ក្នុងគោលការណ៍ណែនាំបច្ចេកទេសនេះ មានការបង្ហាញពីបច្ចេកវិទ្យានីមួយៗ ដែលងាយស្រួលយល់ និងសមស្របសម្រាប់អនុវត្តលើទម្រង់នៃការប្រើប្រាស់ដីផ្សេងៗរបស់កសិករខ្នាតតូចនៅក្នុងប្រទេសកម្ពុជា។

## ២. គោលបំណងនៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំបច្ចេកទេសស្តីពីការអនុវត្តកសិកម្មវៃឆ្លាតខាងអាកាសធាតុសម្រាប់កសិករខ្នាតតូច ត្រូវបានចងក្រងឡើងដើម្បីជាឯកសារជំនួយស្មារតី និងជាត្រីវិស័យតម្រង់ទិសប្រព័ន្ធកសិកម្ម ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងធានាសន្តិសុខស្បៀងក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុសម្រាប់កសិករខ្នាតតូចនៅក្នុងប្រទេសកម្ពុជា។ ឯសារនេះ មានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ផ្តល់នូវព័ត៌មានគ្រឹះសំខាន់ៗដល់អ្នកអភិវឌ្ឍន៍ មន្ត្រីកសិកម្ម ឬភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ស្ថាប័នស្រាវជ្រាវ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្សព្វផ្សាយនិងលើកកម្ពស់ការអនុវត្ត CSA ការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្មបែបឆ្នៃប្រឌិតសមស្រប។
- បង្កើនការយល់ដឹង និងកសាងចំណេះដឹងនិងសមត្ថភាពរបស់កសិករ និងអ្នកពាក់ព័ន្ធ លើការរួមបញ្ចូលបច្ចេកវិទ្យាសមស្របទៅក្នុងការអនុវត្ត CSA ទៅតាមប្រភេទនៃការប្រើប្រាស់ដីរបស់កសិករ។
- ជំរុញការសម្របសម្រួលរវាងភាគីពាក់ព័ន្ធទាំងអស់ ដែលមានតួនាទីចាំបាច់ក្នុងការផ្សព្វផ្សាយ ពង្រីក និងលើកកម្ពស់ការអនុវត្ត CSA ដល់កសិករ។
- ជំរុញការអនុវត្ត CSA និងពង្រីកការអនុវត្ត CSA សម្រាប់កសិករខ្នាតតូចនៅក្នុងប្រទេសកម្ពុជា។

## ៣. គោលគំនិតនៃ CSA

### ៣.១. និយមន័យ

**កសិកម្មវៃឆ្លាតខាងអាកាសធាតុ** គឺជាសំណុំនៃការអនុវត្តបច្ចេកទេសប្រព័ន្ធកសិកម្ម ដែលអាចបង្កើនផលិតភាព ធន់ទៅនឹងអាកាសធាតុ កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងពង្រឹងការសម្រេចបាននូវសន្តិសុខស្បៀងនិងគោលដៅអភិវឌ្ឍន៍ជាតិ (ក្រសួងបរិស្ថាន, ២០១៧)។

CSA រួមបញ្ចូលនូវវិធីសាស្ត្រដែលផ្លាស់ប្តូរប្រព័ន្ធកសិកម្មឆ្ពោះទៅរកការអនុវត្តដែលមានលក្ខណៈបៃតង ហើយធន់នឹងការប្រែប្រួលអាកាសធាតុ ដោយឈរលើគោលគន្លឹះចំនួន ៣ ដូចខាងក្រោម៖

១. ***ការបង្កើនផលិតភាព និងប្រាក់ចំណូលកសិកម្មប្រកបដោយចីរភាព៖*** ផលិតអាហារដែលមានគុណភាពកាន់តែខ្ពស់ដោយមិនដាក់សម្ពាធបន្ថែមលើធនធានធម្មជាតិ លើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងបង្កើនប្រាក់ចំណូលសម្រាប់កសិករ។

២. ***ការបន្សាំ និងការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ៖*** កាត់បន្ថយភាពងាយរងគ្រោះដោយសារគ្រោះរាំងស្ងួត ទឹកជំនន់ សត្វល្អិត ជំងឺ និងហានិភ័យនៃព្រឹត្តការណ៍អាកាសធាតុខុសប្រក្រតីផ្សេងៗ និងបង្កើនសមត្ថភាពបន្សាំទៅនឹងបញ្ហាប្រឈមរយៈពេលវែងដូចជា ការកើនឡើងនៃការប្រែប្រួលធាតុអាកាសតាមរដូវ ឬគំរូអាកាសធាតុខុសប្រក្រតី។



៣. ***ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់៖*** កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីប្រព័ន្ធផលិតកម្មស្បៀង ជៀសវាងការកាប់បំផ្លាញព្រៃឈើដោយសារការពង្រីកដីដាំដំណាំ និងបង្កើនការស្រូបកាបូនរបស់រុក្ខជាតិ និងដី (World Bank, 2024)។

### ៣.២. ក្រុមគោលដៅអនុវត្ត CSA និងវិសាលភាព

ឯកសារនេះ ត្រូវបានរៀបចំឡើងដើម្បីជាឯកសារជំនួយស្មារតី និងត្រីវិស័យតម្រង់ទិស សម្រាប់មន្ត្រីជំនាញថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម អង្គការដៃគូពាក់ព័ន្ធ អ្នកស្រាវជ្រាវ វិស័យឯកជន កសិករ ឬសហគមន៍កសិករ ក្នុងការជំរុញការអនុវត្ត និងការពង្រីកការអនុវត្ត CSA ដល់កសិករខ្នាតតូចនៅកម្ពុជា។

គោលការណ៍ណែនាំនេះ មានវិសាលភាពគ្របដណ្តប់លើកសិករខ្នាតតូចដែលពឹងអាស្រ័យលើការដាំដុះដំណាំ និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ប៉ុន្តែមិនគ្របដណ្តប់លើកសិករដាំដុះដំណាំខ្នាតឧស្សាហកម្ម ពាណិជ្ជកម្ម និងចិញ្ចឹមសត្វជាលក្ខណៈកសិដ្ឋានខ្នាតធំឡើយ។

## ៤. សារៈប្រយោជន៍នៃការអនុវត្ត CSA

ការអនុវត្ត CSA ផ្តល់នូវសារៈប្រយោជន៍ជាច្រើនដល់ផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន ដូចខាងក្រោម៖

- បង្កើនផលិតភាពដាំដុះ និងរក្សាបានចរន្តផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ទីផ្សារ
- ចំណាយកម្លាំងពលកម្មតិច និងបង្កើនប្រាក់ចំណូលសម្រាប់កសិករ
- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងការកាត់បន្ថយការចំណាយថ្លៃដើម
- បង្កើនភាពធន់ និងពង្រឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- ធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស
- ធ្វើឱ្យគុណភាពដីប្រសើរឡើង និងរក្សាបាននិរន្តរភាពប្រព័ន្ធអេកូឡូស៊ី និងធនធានបរិស្ថាន ។ល។




## ៥. បច្ចេកវិទ្យា និងការអនុវត្ត CSA

បច្ចេកវិទ្យា និងការអនុវត្ត CSA សមស្របត្រូវបានកំណត់អត្តសញ្ញាណនៅលើមូលដ្ឋាននៃព័ត៌មានដែលប្រមូលបាននៅក្នុងអំឡុងពេលការធ្វើបង្ហាញ (Farm Demonstration) ការស្ទង់មតិ ការស្រាវជ្រាវ រួមជាមួយនឹងចំណេះដឹងរបស់អ្នកជំនាញ។ បច្ចេកវិទ្យា និងការអនុវត្ត CSA ដែលគួរអនុវត្តមានបង្ហាញនៅក្នុងតារាងទី១ ខាងក្រោម៖

តារាងទី១៖ បច្ចេកវិទ្យាសមស្របសម្រាប់អនុវត្តកសិកម្មវៃឆ្លាត

| ផ្នែកអនុវត្ត | ការអនុវត្ត | បច្ចេកវិទ្យាសមស្របសម្រាប់អនុវត្តកសិកម្មវៃឆ្លាត |
|---|---|---|
| បច្ចេកវិទ្យា និងការដាំដុះដំណាំ  | • ការប្រមូលទឹក និងការស្តុកទុកសម្រាប់ស្រោចស្រព  | 1. ប្រើប្រាស់ពាងទឹក ស៊ីទែនទឹក ឬអាងបេតុងស្តុកទឹកសម្រាប់រក្សាទឹកតុកសម្រាប់ស្រោចស្រព<br>2. ជីកស្រះ ឬអណ្តូងលូសម្រាប់ជាប្រភពទឹក<br>3. បង្កើតផ្ទៃរងទឹកភ្លៀងសម្រាប់ប្រមូលទឹកភ្លៀង<br>4. បង្កើតហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដែលងាយស្រួល និងសមស្របសម្រាប់កសិករ ត្រងទឹក ប្រមូលទឹក ស្តុកទឹក។ល។ |
| | • ការស្រោចស្រពដំណាំ  | 5. ប្រើប្រាស់ប្រព័ន្ធទុយយោបន្សាចទៅតាមប្រភេទដំណាំ (ឧ. ដំណាំបន្លែយកស្លឹក ផ្លែ ឬមើម...) និងប្រភេទដី<br>6. ប្រើប្រាស់ប្រព័ន្ធទុយយោដំណក់ទឹក ទៅតាមប្រភេទដំណាំ (ឧ. ដំណាំបន្លែយកផ្លែ ឬមើម ឈើហូបផ្លែ...) និងប្រភេទដី<br>7. ប្រើប្រាស់ទុយយោបូមបាញ់ ឬបូមបង្ហៀរទៅតាមសណ្ឋានដី ឬធនធានដែលមាន<br>8. ជីកប្រឡាយសម្រាប់បង្ហៀរ ឬរំដោះការជាំទឹក ។ល។ |
| | • កសិរុក្ខកម្ម  | 9. អនុវត្តបច្ចេកទេសតុងយ៉ា (Taungya) នៅតំបន់ជម្រាល<br>10. អនុវត្តបច្ចេកទេសគេហ៍សួន និងដំណាំច្រើនស្រទាប់<br>11. ដាំដំណាំជារបាំងការពារខ្យល់ |
| | • កសិកម្មអភិរក្ស  | 12. ដាំដំណាំគម្របដី ឬពពួកដំណាំកំពកឫស<br>13. កាត់បន្ថយការរំខានដល់ដី (កាត់បន្ថយការភ្ជួររាស់...)<br>14. គ្របគល់ដំណាំដោយសំណល់កសិកម្ម ដើម្បីបង្កើនជីជាតិដី និងរក្សាសំណើមដី<br>15. គ្រប់គ្រងសំណល់កសិកម្មនៅក្នុងកសិដ្ឋាន។ល។ |
| | • ការគ្រប់គ្រងគុណភាពដី  | 16. ប្រើប្រាស់ជីកំប៉ុស (ឧ. កំប៉ុសទឹក សួត ...)<br>17. ប្រើប្រាស់ជីលាមកគោ/ក្របី/មាន់/ទា/ជ្រូក...<br>18. ប្រើប្រាស់ជីសរីរាង្គផ្សេងៗ<br>19. ប្រើប្រាស់សំណល់កសិកម្ម ឬរក្សាសំណល់កសិកម្ម<br>20. ដាំដំណាំដែលបង្កើនជីជាតិដល់ដី (ឧ. ពពួកសណ្តែក ឬពពួកដំណាំកំពកឫស...)។ល។ |
| | • ការគ្រប់គ្រងដំណាំ  | 21. ប្រើប្រាស់ពូជថ្មីៗដែលមានរយៈពេលខ្លី ទិន្នផលនិងទីផ្សារខ្ពស់ ធន់នឹងជំងឺ ធន់នឹងគ្រោះរាំងស្ងួត ធន់នឹងទឹកជំនន់ ។ល។ |

| | | |
|---|---|---|
| | | 22. អនុវត្តវិធានការ IPM (Integrated Pest Management)<br>23. ប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ (ឧ. ការបញ្ជាស្រោចស្រពស្វ័យប្រវត្ត ការពិនិត្យសំណើមដី...)<br>24. ការប្រើប្រាស់ផ្លាស្ទិកគ្របគល់ដើម្បីកាត់បន្ថយស្មៅចង្រៃ ទីជម្រកកត្តាចង្រៃ និងកាត់បន្ថយការបំភាយចំហាយទឹក<br>25. ដាំដុះដំណាំនៅក្នុងផ្ទះសំណាញ់ ផ្ទះកញ្ចក់ ឬរោងកៃច្នៃ<br>26. ដាំដុះលើទឹក (Hydroponic) ដាំលើធ្នើ។ល។ |
| | • ថាមពល<br> | 27. ប្រើប្រាស់ថាមពលកកើតឡើងវិញ (ឧ. សូឡាបូមទឹក...)<br>28. ទាញទឹកដោយបច្ចេកទេសបុរាណផ្សេងៗ (ឧ. រហាត់ទឹក)<br>29. ទម្លាក់ទឹកពីស៊ីទែន ឬពាង ឬធុង ឬអាងស្តុកទឹក ឬពីប្រភពផ្សេងទៀត (ឧ. ទឹកជ្រោះ ទឹកធ្លាក់...) ដើម្បីស្រោចស្រព<br>30. ស្រោចស្រពដោយប្រើប្រាស់ម៉ាស៊ីនដែលសន្សំសំចៃប្រេងឥន្ធនៈខ្ពស់ ឬម៉ាស៊ីនដែលប្រើប្រាស់ហ្គាសដែលចេញពីឡជីវៈឧស្ម័ន។ល។ |
| បច្ចេកវិទ្យា និងការចិញ្ចឹមសត្វ<br> | • ការបង្កាត់ពូជថ្មីៗ<br> | 31. ប្រើប្រាស់ពូជសត្វដែលធន់នឹងជំងឺ លូតលាស់ធំធាត់លឿន<br>32. ប្រើប្រាស់ពូជដែលមានគុណភាពល្អ និងមានតម្រូវការទីផ្សារខ្ពស់។ល។ |
| | • ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងចំណី<br> | 33. ដាំប្រភេទស្មៅចំណី ដែលធ្វើឱ្យសត្វធំធាត់លឿន<br>34. ដាំប្រភេទស្មៅចំណីតាមចន្លោះរងដំណាំ ឬផ្នែកមួយនៃចម្ការ<br>35. រៀបចំតំបន់វាលស្មៅសម្រាប់គោ ក្របី មាន់ ទា។ល។ |
| | • ការគ្រប់គ្រងលាមកសត្វ<br> | 36. ប្រើប្រាស់លាមកសត្វ សម្រាប់ឡជីវឧស្ម័នក្នុងការទាញយកថាមពល និងសំណល់ឡជីវៈឧស្ម័ន (Bioslurry) សម្រាប់ប្រើប្រាស់ធ្វើជី ដាក់ដំណាំកសិកម្ម<br>37. ធ្វើជីកំប៉ុសសម្រាប់ប្រើប្រាស់លើដំណាំកសិកម្ម។ល។ |
| | • ការប្រើប្រាស់ឡជីវៈឧស្ម័ន<br> | 38. ប្រើប្រាស់ឡជីវឧស្ម័នសម្រាប់ទាញយកថាមពលប្រើប្រាស់ ហើយសំណល់ឡជីវៈឧស្ម័ន (Bioslurry) អាចប្រើប្រាស់ធ្វើជី ដាក់ដំណាំកសិកម្ម<br>39. ប្រើប្រាស់ឡជីវៈឧស្ម័នដើម្បីគ្រប់គ្រងលាមកសត្វ។ល។ |

| | |
|---|---|
| ការនេសាទ និងវារីវប្បកម្ម | • ការនេសាទដោយនិរន្តរភាព |
| | • ការចិញ្ចឹមត្រីក្នុងស្រះ |
| | • ការចិញ្ចឹមត្រីក្នុងស្រែ |
| | • ការចិញ្ចឹមត្រីក្នុងបែ ឬវារីវប្បកម្មចម្រុះ |
| បច្ចេកវិទ្យា និងការអនុវត្តផ្សេងៗ | • ការចិញ្ចឹមឃ្មុំ |
| | • ធ្វើឱ្យប្រសើរឡើងបច្ចេកវិទ្យាក្រោយការប្រមូលផល |
| | • សេវាកម្មព័ត៌មានអាកាសធាតុ |

## ៦. តួនាទី និងអភិក្រមសម្រាប់ការពង្រីកការអនុវត្ត CSA

ដើម្បីឱ្យការអនុវត្ត CSA ទទួលបានជោគជ័យ និងមាននិរន្តរភាព ត្រូវការជាចាំបាច់នូវការចូលរួមយ៉ាងសកម្មរបស់កសិករ និងការគាំទ្រពីរាជរដ្ឋាភិបាល ដៃគូរអភិវឌ្ឍន៍ អង្គការនានា វិស័យឯកជន ស្ថាប័នស្រាវជ្រាវដៃគូ និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីជួយសម្របសម្រួល ផ្តល់បច្ចេកទេស ស្វែងរកទីផ្សារ កៀរគរធនធាន និងផ្សព្វផ្សាយ។ គោលការណ៍ណែនាំនេះ បានគូសបញ្ជាក់ពីតួនាទីរបស់ស្ថាប័ន និងអ្នកពាក់ព័ន្ធពាក់ព័ន្ធ ក៏ដូចជាអភិក្រមសម្រាប់អនុវត្ត CSA ដោយឈរលើយេនឌ័រ និងការចូលរួមរបស់កសិករ ឬសហគមន៍ ដើម្បីពង្រីកការអនុវត្តឱ្យបានទូលំទូលាយ។

### ៦.១. តួនាទីរបស់ស្ថាប័ន/អ្នកពាក់ព័ន្ធក្នុងការអនុវត្ត និងពង្រីកការអនុវត្ត CSA

ភាគីពាក់ព័ន្ធ និងតួនាទីរបស់ពួកគេនៅក្នុងការអនុវត្ត និងការពង្រីកការអនុវត្ត CSA មានចែងលម្អិតដូចខាងក្រោម៖

#### ក. រាជរដ្ឋាភិបាល

ស្ថានប័នរបស់រាជរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានតួនាទីសំខាន់ៗពាក់ព័ន្ធការអនុវត្ត និងពង្រីកការអនុវត្ត CSA ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ កម្មវិធីពាក់ព័ន្ធនិងឯកសារពាក់ព័ន្ធផ្សេងទៀត ដែលគាំទ្រដល់ការអនុវត្ត CSA។
- គាំទ្រ និងជំរុញការអនុវត្ត CSA ឱ្យមានដំណើរការកាន់តែល្អប្រសើរសម្រាប់កសិករ
- កសាងសមត្ថភាពអាជ្ញាធរមូលដ្ឋាន និងប្រជាកសិករអំពីបច្ចេកទេស CSA និងផ្សព្វ-



ផ្សាយអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការអនុវត្តបច្ចេកវិទ្យាកសិកម្មសមស្រប និងជោគជ័យដល់កសិករ។ ការផ្សព្វផ្សាយអាចត្រូវបានធ្វើដោយប្រើមធ្យោបាយផ្សេងៗដូចជា វិទ្យុ ទូរទស្សន៍ កាសែត ប្រព័ន្ធផ្សព្វផ្សាយសង្គម ការតាំងពិពណ៌របស់កសិករ ជាដើម។

- កសាងសមត្ថភាពមន្ត្រី ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅគ្រប់កម្រិត ពីបច្ចេកទេស និងការអនុវត្ត CSA ដែលមានស្រាប់ កែលម្អថ្មី ឬបង្កើតថ្មី។
- បង្កើនភាពជាដៃគូ ឬកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន និងអង្គការដៃគូពាក់ព័ន្ធ ដែលធ្វើការពាក់ព័ន្ធនឹងបច្ចេកវិទ្យា និង/ឬការអនុវត្ត CSA នៅមូលដ្ឋាន។
- គាំទ្រផ្នែកហិរញ្ញវត្ថុ និងបង្កើនការចំណាយសាធារណៈទៅក្នុងការស្រាវជ្រាវ ការអភិវឌ្ឍន៍ ការថ្លៃប្រឌិត និងនវានុវត្តន៍ លើបច្ចេកវិទ្យា CSA។
- គាំទ្រវិស័យឯកជនឱ្យវិនិយោគលើការការអនុវត្ត CSA ដែលជោគជ័យ។
- ជំរុញការប្រកាសព័ត៌មានឱ្យដឹងមុន អំពីព័ត៌មានអាកាសធាតុ ឬឧតុនិយម ដើម្បីជួយកសិករ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការបង្កើនកម្រិតត្រៀមបង្ការ និងការអនុវត្តបច្ចេកវិទ្យា CSA ដែលសមស្រប។
- បង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត CSA និងការពង្រីកការផ្សព្វផ្សាយពីការអនុវត្ត CSA ដល់តំបន់ផ្សេងៗទៀត។ល។

## ខ. ដៃគូអភិវឌ្ឍន៍ និងអង្គការដៃគូនានា

ដៃគូអភិវឌ្ឍន៍ និងអង្គការដៃគូនានាមានតួនាទីសំខាន់ៗពាក់ព័ន្ធនឹងការអនុវត្ត និងការពង្រីកការអនុវត្ត CSA ដូចខាងក្រោម៖

- ផ្តល់ជំនួយបច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗដែលសមស្របទៅនិងតំបន់កៀ្សត្របរិស្ថានផ្សេងៗ។
- គាំទ្រ និងសម្របសម្រួលគំនិតផ្តួចផ្តើមកសាងសមត្ថភាពដល់កសិករ អ្នកផ្សព្វផ្សាយកសិកម្ម និងអ្នកពាក់ព័ន្ធផ្សេងៗ អំពីបច្ចេកវិទ្យាសមស្រប និងការអនុវត្ត CSA។
- ជំរុញការផ្សព្វផ្សាយ និងពង្រីកការអនុវត្ត CSA ដែលជោគជ័យទៅតំបន់ផ្សេង។
- បង្កើនការធ្វើបង្ហាញនៅកម្រិតកសិដ្ឋាន និងរៀបចំនិងគាំទ្រដំណើរទស្សនកិច្ចសិក្សាសម្រាប់កសិករ ដើម្បីបង្កើនការទទួលយកបច្ចេកវិទ្យា និងការអនុវត្ត CSA ដែលមានស្រាប់ កែលម្អថ្មីជាដើម។
- ស្វែងរកទីផ្សារ ភ្ជាប់កសិករទៅទីផ្សារនិងអ្នកផ្តល់ធាតុចូលនិងសេវាកម្ម ដើម្បីធានានិរន្តរភាពនៃការអនុវត្ត CSA។
- លើកកម្ពស់ចំណេះដឹងជនជាតិដើមភាគតិច ស្ត្រី និងជនមានពិការភាព លើការអនុវត្ត CSA។
- ចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការស្វែងរកទីផ្សារ បង្កើតទីផ្សារ និងការភ្ជាប់កសិករទៅទីផ្សារ។
- ចូលរួមសម្របសម្រួល តាមដានការអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃការងារអនុវត្ត CSA។
- ចងក្រងក្រុមកសិករ ឬសហគមន៍កសិករ សម្រាប់អនុវត្ត CSA និងលក់ផលិតផលកសិកម្ម។

## គ. វិស័យឯកជន

វិស័យឯកជនមានតួនាទីសំខាន់ៗ ពាក់ព័ន្ធការអនុវត្ត និងការពង្រីកការអនុវត្ត CSA ដូចខាងក្រោម៖

- កំណត់ឱកាសអនុវត្ត និងគាំទ្រផលិតផលដែលកសិករផលិតបាន។

- អភិវឌ្ឍទីផ្សារ បង្កើត និងពង្រីកទីផ្សារដល់តំបន់មូលដ្ឋានរបស់កសិករ។
- ចង្អុរបង្ហាញលើប្រភេទដំណាំគោលដៅ ដែលជាតម្រូវការចម្បងរបស់ទីផ្សារ។

### ឃ. ស្ថាប័នស្រាវជ្រាវដៃគូ

ស្ថាប័នស្រាវជ្រាវដៃគូ មានតួនាទីសំខាន់ៗពាក់ព័ន្ធការអនុវត្ត និងការពង្រីកការអនុវត្ត CSA ដូចខាងក្រោម៖

- ស្រាវជ្រាវដោយមានការចូលរួមពីដៃគូពាក់ព័ន្ធ អ្នកជំនាញដើម្បីកែលម្អបច្ចេកវិទ្យាមានស្រាប់ ឬស្វែងរកបច្ចេកវិទ្យាថ្មីៗដែលធន់ ងាយស្រួលអនុវត្ត និងសមស្របសម្រាប់តំបន់ក្សេត្របរិស្ថានផ្សេងៗ។
- ផ្សព្វផ្សាយនូវបច្ចេកវិទ្យា CSA ដែលកែលម្អថ្មី ឬរកឃើញថ្មីសម្រាប់កសិករ និងអ្នកអនុវត្តផ្សេងៗ។
- កសាងសមត្ថភាពមន្ត្រី ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម កសិករ និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅគ្រប់កម្រិតពីបច្ចេកទេស និងការអនុវត្ត CSA ដែលមានស្រាប់ កែលម្អថ្មី ឬថ្មី។
- បោះពុម្ពឯកសារវិទ្យាសាស្ត្រ ទស្សនាវដ្ដី ខិតប័ណ្ណផ្សព្វផ្សាយ ពីលទ្ធផលស្រាវជ្រាវជាខេមរភាសា ដែលងាយអាន ងាយយល់សម្រាប់កសិករ និងអ្នកពាក់ព័ន្ធគ្រប់កម្រិត។

### ង. ប្រព័ន្ធផ្សព្វផ្សាយ

ប្រព័ន្ធផ្សព្វផ្សាយមានតួនាទីសំខាន់ៗពាក់ព័ន្ធការអនុវត្ត និងការពង្រីកការអនុវត្ត CSA ដូចខាងក្រោម៖

- ស្វែងរក និងផ្សព្វផ្សាយព័ត៌មាន CSA ដែលបានស្រាវជ្រាវ និងអនុវត្តជោគជ័យ។
- រៀបចំឱ្យមាន Platform សម្រាប់កសិករផ្សព្វផ្សាយបច្ចេកទេស CSA។
- ផ្សព្វផ្សាយពីបច្ចេកវិទ្យា CSA ល្អ ឬជោគជ័យ លើប្រព័ន្ធផ្សព្វផ្សាយដូចជា វិទ្យុ ទូរទស្សន៍ បណ្ដាញផ្សព្វផ្សាយសង្គម គេហទំព័រ...។

### ច. កសិករ និង/ឬ សហគមន៍កសិករ

កសិករ និង/ឬសហគមន៍កសិករមានតួនាទីសំខាន់ៗពាក់ព័ន្ធការអនុវត្ត និងការពង្រីកការអនុវត្ត CSA ដូចខាងក្រោម៖













- ការតាំងចិត្ត និងការប្តេជ្ញាចិត្តអនុវត្ត។
- មានធនធានសមស្រប (ដីសម្រាប់ដាំដុះ កម្លាំងពលកម្ម...)។
- មុខរបរកសិកម្ម ឬការដាំដុះដំណាំជាមុខរបរចម្បងរបស់- កសិករ។
- ចងក្រងក្រុមកសិករ ឬសហគមន៍កសិករ សម្រាប់អនុវត្ត CSA និងលក់ផលិតផលកសិកម្ម។
- ចូលរួមវគ្គបណ្តុះបណ្តាល និងបន្តរៀនសូត្រពីបច្ចេកទេសដាំដុះដំណាំ។
- ចូលរួមទស្សនកិច្ចសិក្សា និងស្វែងយល់ពីការអនុវត្ត CSA របស់កសិករជោគជ័យ។

### ឆ. តួនាទីរបស់អាជ្ញាធរមូលដ្ឋាន (ស្រុក ឃុំ ភូមិ)

តួនាទីរបស់អាជ្ញាធរមូលដ្ឋាន (ស្រុក ឃុំ ភូមិ) មានតួនាទីសំខាន់ៗពាក់ព័ន្ធការអនុវត្ត និងការពង្រីកការអនុវត្ត CSA ដូចខាងក្រោម៖

- គាំទ្រ និងលើកទឹកចិត្តដល់ការអនុត្ត CSA របស់កសិករ។
- ផ្សព្វផ្សាយនូវបច្ចេកវិទ្យា CSA ដែលកសិករអនុវត្តជោគជ័យ។
- ចូលរួមសម្របសម្រួល ដោះស្រាយទំនាស់ដីធ្លី និងការប្រើប្រាស់ធនធាននៅក្នុងសហគមន៍ក្នុងករណីមានការបំពានខុសច្បាប់។
- ស្វែងរកមូលនិធិគាំទ្រ និងទីផ្សារ ជូនកសិករ និងសហគមន៍។

## ៦.២. អភិក្រមក្នុងការអនុវត្ត និងពង្រីកការអនុវត្ត CSA

អភិក្រមសម្រាប់អនុវត្ត និងការពង្រីក CSA គួរផ្តោតសំខាន់លើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង វប្បធម៌ ប្រពៃណីរបស់សហគមន៍ ជាពិសេសស្ត្រី និងជនជាតិដើម។
- វិធីសាស្ត្រដោយផ្អែកលើសហគមន៍។
- ការស្រាវជ្រាវ ការរៀនសូត្រ និងការបណ្តុះបណ្តាលកសិករ៖ រួមបញ្ចូលកម្មសិក្សារបស់កសិករ វិធីសាស្ត្រអនុវត្តប្រព័ន្ធកសិកម្ម វិធីសាស្ត្រផ្សព្វ-ផ្សាយរវាងកសិករ និងកសិករ យុទ្ធនាការរបស់កសិករជាដើម។
- ការទូទាត់សម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី។
- វេទិកានវានុវត្តន៍ ដោយមានការចូលរួមពីអ្នកសម្របសម្រួលកសិករ ភ្នាក់-ងារផ្សព្វផ្សាយកសិកម្ម កសិករ អាជ្ញាធរមូលដ្ឋាន។ល។
- ចែករំលែកចំណេះដឹងនិងព័ត៌មានតាមរយៈយុទ្ធនាការបណ្តុះបណ្តាល ឬផ្សព្វផ្សាយតាមបណ្តាញសង្គម វិទ្យុ ទូរទស្សន៍ ការសែត ជាដើម។
- ការសម្របសម្រួលត្រូវធ្វើឡើងដោយអ្នកជំនាញ និងអ្នកពាក់ព័ន្ធផ្សេងៗ។
- ទំនាក់ទំនងទីផ្សារប្រកបដោយនិរន្តរភាព។

## ៦.៣. ការធ្វើបង្ហាញ (Demonstration) ដើម្បីពង្រីកការអនុវត្ត CSA

ការអនុវត្ត CSA ជាជំហានដ៏សំខាន់ដើម្បីបង្កើននិងពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់កសិករ។ ក្នុងន័យនេះ ការធ្វើបង្ហាញពី CSA ជាមួយកសិករខ្នាតតូច គឺជាគំនិតផ្តួចផ្តើមដែលបង្កើតឡើងដើម្បីលើកកម្ពស់ការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព បង្កើនផលិតភាព និងពង្រឹងភាពធន់ក្នុងចំណោមសហគមន៍ជនបទដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ។ វិធីសាស្ត្រផ្អែកលើការធ្វើបង្ហាញនេះបង្ហាញពីបច្ចេក-ទេសកសិកម្មដែលមានលក្ខណៈជាក់ស្តែង និងសម្របតាមស្ថានភាពកសិដ្ឋានខ្នាតតូច ធ្វើឱ្យកសិករអាចសង្កេត រៀន និងទទួលយកការច្នៃប្រឌិតដែលបង្កើនផលិតភាព ទិន្នផល ប្រាក់ចំណូល និងភាពធន់របស់ពួកគេ។ តាមរយៈការធ្វើបង្ហាញបច្ចេកវិទ្យា CSA ដែលផ្តល់ផលចំណេញខ្ពស់ដល់កសិករ វានឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ពង្រីកវិស័យកសិកម្មប្រកបដោយនិរន្តរភាពនៅទូទាំងតំបន់ដែលងាយរងគ្រោះ។

ការធ្វើបង្ហាញ CSA រួមបញ្ចូលនូវការអនុវត្តបច្ចេកវិទ្យាកសិកម្មសមស្រប ដែលមានបង្ហាញនៅផ្នែកទី ៥ (បច្ចេកវិទ្យា និងការអនុវត្ត CSA) ក្នុងតារាងទី១ ធនធាន កម្លាំងពលកម្ម និងការតាំងចិត្តរបស់កសិករជាដើម។ ការធ្វើបង្ហាញនេះ នឹងចែករំលែកចំណេះដឹងពីកសិករមួយទៅកសិករមួយផ្សេងទៀត ហើយវានឹងផ្តល់សិទ្ធិអំណាចដល់កសិករខ្នាតតូចក្នុងការសម្រេចចិត្តជ្រើសរើសវិធីសាស្ត្រដាំដុះ ស្រោចស្រព និងប្រភេទដំណាំដែលធន់នឹងអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ កសិករដែលមានធនធានសមស្រប ហើយពឹងអាស្រ័យលើការដាំដុះដំណាំជាមុខរបរចម្បង គឺជាមុខសញ្ញាសម្រាប់ជ្រើសរើសធ្វើបង្ហាញ CSA សម្រាប់កសិករផ្សេងទៀត។ ការធ្វើបង្ហាញ CSA មានជំហានសំខាន់ៗចំនួន ៧ ដូចមានបង្ហាញនៅក្នុងដ្យាក្រាមខាងក្រោម៖



### ក. ជំហានទី១ ការចុះស្ទាបស្ទង់ពីចំណាប់អារម្មណ៍របស់កសិករ

ការចុះស្ទាបស្ទង់ពីចំណាប់អារម្មរបស់កសិករគួរមានសកម្មភាពដូចខាងក្រោម៖

- ការចុះសិក្សា និងចុះស្ទាបស្ទង់អំពីចំណាប់អារម្មរបស់កសិករ ដោយប្រើប្រាស់បញ្ជីរសំណួរ។
- ការអង្កេតស្ថានភាពការអនុវត្តបច្ចេកវិទ្យាកសិកម្ម ប្រភេទដំណាំ ទីផ្សារ ឬបច្ចេកទេសដាំដុះមានស្រាប់នៅក្នុងតំបន់គោលដៅ។
- ការប្រើប្រាស់ផ្លូវ ដើម្បីពិនិត្យមើលលើទិដ្ឋភាពកសិដ្ឋានមានស្រាប់ និងប្រព័ន្ធគ្រប់គ្រងបរិស្ថានមានស្រាប់។
- ការពិគ្រោះយោបល់ និងការស្វែងរកកិច្ចគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូរពាក់ព័ន្ធ។

### ខ. ជំហានទី២ ការជ្រើសរើសកសិករធ្វើបង្ហាញ

ការជ្រើសរើសកសិករធ្វើបង្ហាញគួរគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម៖

- ជាកសិករខ្នាតតូច ហើយមុខរបរកសិកម្ម ឬការដាំដុះដំណាំជាមុខរបរចម្បងរបស់គ្រួសារ។
- ជាកសិករដែលស្ថិតនៅក្នុងតំបន់គោលដៅរបស់ស្ថាប័នអនុវត្តគម្រោងណាមួយរបស់ស្ថាប័នដៃគូរ ឬអង្គការដៃគូរ។
- ជាកសិករដែលមានការតាំងចិត្ត និងការប្តេជ្ញាចិត្តអនុវត្តខ្ពស់។
- ជាកសិករមានធនធានសមស្រប (ដីសម្រាប់ដាំដុះ កម្លាំងពលកម្ម)។
- ជាកសិករដែលមានភាពប៉ិនប្រសប់ ច្នៃប្រឌិត និងមានភាពបត់បែនលឿន។

### គ. ជំហានទី៣ ការផ្តល់វគ្គបណ្តុះបណ្តាលលើបច្ចេកវិទ្យា CSA

ការផ្តល់វគ្គបណ្តុះបណ្តាលលើបច្ចេកវិទ្យា CSA គួរអនុវត្តដូចខាងក្រោម៖

- មុនរៀបចំវគ្គបណ្តុះបណ្តាល ការពិភាក្សាជាមួយកសិករគួររៀបចំឡើងដើម្បីស្វែងយល់ស្ថានភាពការអនុវត្តបច្ចេកវិទ្យាកសិកម្ម ប្រភេទដំណាំ ទីផ្សារ ឬបច្ចេកទេសដាំដុះមានស្រាប់នៅក្នុងតំបន់គោលដៅ។
- ការផ្តល់វគ្គបណ្តុះបណ្តាល ត្រូវផ្តោតសំខាន់លើប្រធានបទទៅតាមតម្រូវការជាក់ស្តែងរបស់កសិករ និងលទ្ធផលដែលចេញពីការពិភាក្សាជាមួយកសិករ (ឧ. បច្ចេកទេសជ្រើសរើសពូជ រៀបចំដី ដាំដុះ ស្រោចស្រព ថែទាំ និងប្រមូលផលរបស់បន្លែ ឈើហូបផ្លែ ចិញ្ចឹមសត្វ ធ្វើជីកំប៉ុស។ល។)
- រយៈពេលនៃវគ្គបណ្តុះបណ្តាលអាចរៀបចំទៅតាមតម្រូវការចាំបាច់ និងជាក់ស្តែង។
- ទីតាំងរៀបចំវគ្គបណ្តុះបណ្តាលបណ្តាលអាចរៀបចំនៅទីតាំងសមស្របដូចជា សាលប្រជុំរបស់ស្ថាប័នរដ្ឋ ឯកជន អង្គការដៃគូ ឬនៅសាលាឆទាន ស្នាក់ការសហគមន៍ ឬផ្ទះប្រជាពលរដ្ឋ។ល។
- សមាសភាពអ្នកចូលរួមមាន អាជ្ញាធរមូលដ្ឋាន អង្គការដៃគូរ កសិករគោលដៅ។ល។

### ឃ. ជំហានទី៤ សិក្ខាសាលាគាំទ្រសេចក្តីសម្រេចចិត្ត (DS) និងការធ្វើផែនការកសិដ្ឋាន

ការផ្លាស់ប្តូរយោបល់ជាមួយកសិករលើបច្ចេកវិទ្យាសមស្រប ការផ្តល់សិក្ខាសាលាគាំទ្រការធ្វើសេចក្តីសម្រេចចិត្ត (Desision Support) និងការធ្វើផែនការកសិដ្ឋាន នឹងផ្តល់សិទ្ធិអំណាចដល់កសិករក្នុងការសម្រេចចិត្ត

ជ្រើសរើសបច្ចេកវិទ្យា CSA សមស្រប និងប្រភេទដំណាំដែលធន់នឹងអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ សិក្ខាសាលាគាំទ្រសេចក្តីសម្រេចចិត្ត (DS) និងការធ្វើផែនការកសិកដ្ឋានគួរអនុវត្តដូចខាងក្រោម៖

- ការអនុញ្ញាតឱ្យមានការពិភាក្សារវាងកសិករទៅកសិករ និងកសិករទៅអ្នកសម្របសម្រួលលើផែនការកសិដ្ឋានទាំងបច្ចុប្បន្ន និងអនាគត។
- ការផ្លាស់ប្តូរបទពិសោធន៍ និងផ្លុះបញ្ចាំងបទពិសោធន៍រវាងកសិករទៅកសិករ និងកសិករទៅអ្នកសម្របសម្រួលលើបច្ចេកវិទ្យា CSA។
- ការពិភាក្សា និងជ្រើសរើសគំរូ CSA ដែលសមស្របសម្រាប់បរិបទក្នុងកសិដ្ឋាននីមួយៗ។
- ការរៀបចំផែនការកសិដ្ឋានរបស់កសិករសម្រាប់ការអនុវត្ត CSA។

### ខ. ជំហានទី៥ ការផ្តល់ពូជដំណាំទៅតាមប្លង់កសិដ្ឋានដែលបានឯកភាព

ការផ្តល់ពូជដំណាំទៅតាមប្លង់កសិដ្ឋានដែលបានឯកភាពលើបច្ចេកវិទ្យា CSA គួរអនុវត្តដូចខាងក្រោម៖

- ការផ្តល់ពូជឈើហូបផ្លែដែលមានតម្លៃសេដ្ឋកិច្ច និងមានតម្រូវការទីផ្សារខ្ពស់ (ឧ. ដូង ក្រូចឆ្មា ក្រូចថ្លុង ក្រូចពោធិសាត់ ធុរេន សាវម៉ៅ មៀន។ល។)
- ការផ្តល់ពូជបន្លែដែលមានតម្រូវការទីផ្សារខ្ពស់ និងធន់ (ឧ. ត្រសក់ ម្រះ ត្រឡាច ននោង ត្របវែង ត្រប់មូល ម្ទេស ឆៃថាវ ត្រកួន ល្ពៅ ឃ្លោក ស្ពៃចង្កឹះ ខាត់ណា ឆៃថាវ សាឡាត់ ពពាយ។ល។)
- ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធកសិដ្ឋាន (ឧ. ស្បៃគ្រប សំណាញ់ទ្រើង ទ្រើង ស្បៃរបង ផ្លាស្ទិកគ្របគល់ ត្រេបណ្តុះកូនបន្លែ។ល។)
- ការគាំទ្រប្រព័ន្ធស្រោចស្រព (ឧ. ទុយយោបន្សាច ទុយយោដំណក់ ស៊ីទែនស្តុកទឹក ទុយយោបូមទឹក ធុងស្រោច។ល។)។

### ច. ជំហានទី៦ ការអនុវត្ត ឬធ្វើបង្ហាញ( Demo ) របស់កសិករ

ការអនុវត្ត ឬធ្វើបង្ហាញ CSA របស់កសិករ គួរអនុវត្តទៅតាមធនធាន ភាពចាំបាច់ កម្លាំងពលកម្ម ទីផ្សារ និងផែនការកសិដ្ឋានដែលបានរៀបចំក្នុងសិក្ខាសាលាគាំទ្រសេចក្តីសម្រេចចិត្ត។ ការធ្វើបង្ហាញ អាចអនុវត្តដោយប្រើប្រាស់បច្ចេកវិទ្យា CSA ដែលបានរៀបរាប់នៅផ្នែកទី៥ ក្នុងតារាងទី១ ទៅតាមប្រភេទដំណាំ។ តារាងទី២ ខាងក្រោមបង្ហាញពីប្រភេទនៃការអនុវត្តការដាំដុះ និងបច្ចេកវិទ្យា CSA សមស្រប។

### ឆ. ជំហានទី៧ ការចុះតាមដាន និងផ្តល់បច្ចេកទេសជាប្រចាំ

ការចុះតាមដាន និងផ្តល់បច្ចេកទេសជាប្រចាំ គួរអនុវត្តដូចខាងក្រោម៖

- ការចុះតាមដានការអនុវត្តរបស់កសិករជាប្រចាំ (អាចប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំឆ្នាំ) ដើម្បីផ្តល់បច្ចេក-ទេស ការអនុវត្ត CSA បញ្ហាប្រឈម។ល។
- ការផ្តល់គ្រាប់ពូជដំណាំបន្លែ និងកូនឈើហូបផ្លែតាមតម្រូវការជាក់ស្តែង ឬចាំបាច់។
- ការនាំយកបច្ចេកទេសថ្មីៗ ដែលសមស្រប និងអាចអនុវត្តបានសម្រាប់កសិករជាប្រចាំ។

តារាងទី២៖ តារាងម៉ាទ្រិកនៃបច្ចេកវិទ្យាសមស្របសម្រាប់អនុវត្ត CSA និងប្រភេទដំណាំ

| **ការអនុវត្ត** | **បច្ចេកវិទ្យាសមស្របសម្រាប់អនុវត្តកសិកម្មវៃឆ្លាត (តារាងទី១)** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 |
| បន្លែ (ស្លឹក មើម ផ្លែ ផ្កា ទង...) | ■ | ■ | | ■ | ■ | ■ | | | | ■ | | ■ | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | ■ | ■ | | | | | | ■ | ■ | ■ | |
| ឈើហូបផ្លែ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | ■ | ■ | | | | ■ | | | ■ | | | | ■ | | ■ | ■ | ■ | |
| បន្លែនៅចន្លោះឈើហូបផ្លែ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | ■ | | ■ | ■ | | | | | | ■ | ■ | ■ | |
| កសិកម្មចម្រុះ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | ■ | | ■ | ■ | | | | | | ■ | ■ | ■ | |
| ដំណាំប្រចាំឆ្នាំវិលជុំចន្លោះឆ្លាស់ឈើហូបផ្លែ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | ■ | | ■ | ■ | | | | | | ■ | ■ | ■ | |
| ដំណាំវិលជុំ | | ■ | ■ | ■ | ■ | | ■ | | | | | ■ | ■ | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | ■ | | | ■ | | | | | | | | | |
| កសិរុក្ខកម្ម | | ■ | ■ | ■ | ■ | ■ | ■ | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | | | | ■ | | | ■ | | | ■ | ■ | | ■ | ■ | ■ | |
| ស្រូវ | | | ■ | | | | ■ | ■ | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | | | | | ■ | ■ | | ■ | | | | | | ■ | ■ | ■ | |
| ចិញ្ចឹមសត្វ (មាន់ ទា គោ ក្របី...) | ■ | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

## ៧. គោលការណ៍សម្រាប់លើកកម្ពស់ និងអនុវត្ត CSA

គោលការណ៍សម្រាប់លើកកម្ពស់ និងអនុវត្ត CSA មាន ៥ ជំហាន ដូចខាងក្រោម៖




### ក. គោលការណ៍ទី១ ការពង្រីក

- ចំនួន និងសមត្ថភាពរបស់កសិករ/សហគមន៍កសិករអនុវត្ត CSA ត្រូវបង្កើននិងកសាងសមត្ថភាពរបស់ពួកគេតាមរយៈការអប់រំ និងការបណ្ដុះបណ្ដាលបន្ថែម។
- កសិករ/សហគមន៍កសិករ ត្រូវលើកទឹកចិត្តតាមរយៈការផ្តល់ភាពងាយស្រួលក្នុងការទទួលបានឥណទានគាំទ្រសមស្របជាមួយអត្រាការប្រាក់សមរម្យរបស់រដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា។
- កសិដ្ឋាន ឬតំបន់ដាំដុះតូចៗ គួរតែចងក្រងទៅជាសហគមន៍កសិកម្ម ឬចង្កោមកសិដ្ឋាន តាមរយៈការស្ម័គ្រចិត្ត គោលនយោបាយ និងបទប្បញ្ញត្តិផ្សេងៗរបស់រដ្ឋាភិបាល។
- លើកកម្ពស់ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ យន្តការ និងបច្ចេកវិទ្យាតាមរយៈថវិកា ឬមូលនិធិអភិវឌ្ឍនានារបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។
- អាជ្ញាធរ និងមន្ទីរជំនាញពាក់ព័ន្ធ ត្រូវលើកទឹកចិត្ត និងស្វែងរកទីផ្សារ ឬបង្កើតទីផ្សារ ដោយផ្តល់អាទិភាពជូនកសិករអនុវត្ត CSA។

### ខ. គោលការណ៍ទី២ ភាពអាចរកបាន និងការទទួលបានហិរញ្ញប្បទាន CSA

- ហិរញ្ញវត្ថុនៃធនាគាររបស់រដ្ឋ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត គួរតែពង្រីកទៅដល់មូលដ្ឋានតាមរយៈគោលនយោបាយ និងបទបញ្ញត្តិផ្សេងៗ។
- ប្រព័ន្ធផ្តល់ឥណទានពិសេសជាមួយអត្រាការប្រាក់ទាប គួរតែត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាល និងវិស័យឯកជន សម្រាប់គាំទ្រដល់ការអនុវត្តរបស់កសិករ។

- បង្កភាពងាយស្រួលដល់កសិករ ឬសហគមន៍កសិករអនុវត្ត CSA លើតំណទាន ដែលមានអត្រាការប្រាក់ទាបសម្រាប់ពង្រីកការអនុវត្ត CSA។
- ក្របខ័ណ្ឌភាពជាដៃគូសាធារណៈនិងឯកជន សម្រាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យានៅក្នុងវិស័យស្បៀងអាហារ កសិកម្ម គប្បីត្រូវបានដំណើរការ និងពង្រឹងបន្ថែមដើម្បីធានាលើការវិនិយោគ និងការផ្សព្វផ្សាយបច្ចេកវិទ្យាប្រកបដោយនិរន្តរភាពតាមខ្សែសង្វាក់តម្លៃទាំងមូល។

### គ. គោលការណ៍ទី៣ ការអប់រំអ្នកផលិត និងអ្នកប្រើប្រាស់

- វិធីសាស្ត្រដែលមានការចូលរួមត្រូវអនុវត្ត និងពង្រឹង នៅពេលដែលការអនុវត្ត CSA នៅកម្រិតសហ-គមន៍ ត្រូវបានពង្រីក ដោយផ្តោតលើតម្លៃសហគ្រិន និងការបន្សាំ។
- ស្ថាប័នជំនាញ ត្រូវគាំទ្រការរៀបចំផ្សព្វផ្សាយពី CSA នៅក្នុងកម្មវិធីកសិកម្មជាតិ និងកម្មវិធីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកម្មវិធីអភិរក្សធនធានធម្មជាតិផ្សេងៗ។
- យុទ្ធសាស្ត្រទំនាក់ទំនងដោយផ្តោតលើ CSA ការអនុវត្តកសិកម្មល្អ (GAP) ក្នុងវិស័យកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ គួរតែត្រូវបានបញ្ជ្រាបជាចម្បងទៅក្នុងគោលនយោបាយ ឬកម្មវិធីអភិវឌ្ឍថ្នាក់ជាតិ។
- ពង្រឹង និងពង្រីកការទទួលបានព័ត៌មានពីហានិភ័យអាកាសធាតុ និងទីផ្សារ ដល់កម្រិតមូលដ្ឋាន។
- ការយល់ដឹងកាន់តែច្រើនអំពីប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ ជាពិសេសទាក់ទងនឹងតួនាទីរបស់អ្នកផលិត (កសិករ) និងអ្នកប្រើប្រាស់ (អ្នកទិញ) នៅក្នុងខ្សែសង្វាក់ផលិត គួរតែត្រូវបានជំរុញតាមរយៈភាពជាដៃគូរវាងសាកលវិទ្យាល័យ-ឧស្សាហកម្ម-រដ្ឋាភិបាល (AIG) សម្រាប់ការស្រាវជ្រាវ ការបណ្តុះ-បណ្តាល និងការកសាងសមត្ថភាព។

### ឃ. គោលការណ៍ទី៤ ឌីជីថល

- ភាពជាដៃគូរបស់រដ្ឋ ជាមួយវិស័យឯកជន ត្រូវពង្រឹងបន្ថែម ដើម្បីពង្រីក និងរក្សាស្ថេរភាពទីផ្សា និងទំនាក់ទំនង។
- ការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាឌីជីថល ជាពិសេសសម្រាប់ទីផ្សារផលិតផលកសិកម្ម គួរតែធ្វើការផ្សព្វផ្សាយ ហើយការផ្សព្វផ្សាយនេះត្រូវធ្វើឡើងតាមរយៈការបញ្ជ្រាបចូលទៅក្នុងកម្មវិធីជាតិផ្សេងៗ។
- ការប្រើប្រាស់វិធីសាស្ត្រកសិកម្មជាក់លាក់តាមរយៈបច្ចេកវិទ្យាឌីជីថលថ្មីត្រូវតែផ្សព្វផ្សាយ និងពង្រីកបន្ថែម។
- គោលនយោបាយ និងកម្មវិធីជាតិ គួរពិនិត្យឡើងវិញដើម្បីផ្លាស់ប្តូរឆ្ពោះទៅរកកសិកម្ម ៤.០ ដែលផ្តោតលើវិស័យកសិកម្មជាក់លាក់ អ៊ីនធឺណិតនៃវត្ថុ (IoT) និងការប្រើប្រាស់ទិន្នន័យធំដើម្បីសម្រេចបាននូវប្រសិទ្ធភាពនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

### ង. គោលការណ៍ទី៥ គោលនយោបាយ និងអភិបាលកិច្ច

- រដ្ឋាភិបាល គួរតែពិចារណាលើការបង្កើត និងអនុវត្តស្តង់ដារជាតិសម្រាប់គោលនយោបាយ និងអភិបាលកិច្ច លើ CSA ដោយផ្អែកលើគោលការណ៍ពាក់ព័ន្ធ។

- រដ្ឋាភិបាល ត្រូវរៀបចំគោលនយោបាយ កម្មវិធីជាតិ ដើម្បីលើកកម្ពស់ការអនុវត្ត CSA ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងធានាសន្តិសុខស្បៀង។
- រៀបចំគោលនយោបាយ និងពង្រឹងការចូលរួមរបស់ស្ត្រី យុវជន និងជនជាតិដើមភាគតិច ជាពិសេសការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យកសិកម្ម និងការប្រែប្រួលអាកាសធាតុ។
- រៀបចំឱ្យមានមន្ត្រីកសិកម្ម ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម ដល់តំបន់មូលដ្ឋាន ដើម្បីផ្តល់បច្ចេកទេសសម្របសម្រួល និងដោះស្រាយបញ្ហាប្រឈមនានាលើការអនុវត្ត CSA។
- ភាពជាដៃគូ និងកិច្ចសហការរវាងសាកលវិទ្យាល័យ-ឧស្សាហកម្ម-រដ្ឋាភិបាល គួរតែលើកកម្ពស់ដើម្បីឆ្លើយតបទៅនឹងតម្រូវការពហុវិស័យ និងអត្ថប្រយោជន៍រួម។

តារាងម៉ាទ្រិក (Matrix) ខាងក្រោម បង្ហាញពីទំនាក់ទំនង និងតួនាទីរបស់ស្ថាប័ន ឬអ្នកពាក់ព័ន្ធនីមួយៗលើគោលការណ៍សម្រាប់លើកកម្ពស់ និងអនុវត្ត CSA។

តារាងទី៣៖ ទំនាក់ទំនង និងតួនាទីរបស់ស្ថាប័ន ឬអ្នកពាក់ព័ន្ធនីមួយៗ លើគោលការណ៍នីមួយៗ

| ស្ថាប័ន/ ភាគីពាក់ព័ន្ធ | គោលការណ៍ | | | | |
|---|---|---|---|---|---|
| | ១ ពង្រីក | ២ ហិរញ្ញប្បទាន | ៣ ការអប់រំ | ៤ ឌីជីថលភាវូបនីយកម្ម | ៥ គោលនយោបាយ និងអភិបាលកិច្ច |
| ក្រសួងជំនាញ និងទីភ្នាក់ងារជាតិពាក់ព័ន្ធនឹង អាហារ កសិកម្ម បសុសត្វ ព្រៃឈើ បរិស្ថាន និងជលផល | √ | √ | √ | √ | √ |
| មន្ទីរជំនាញថ្នាក់ខេត្ត ដែលពាក់ព័ន្ធនឹង អាហារ កសិកម្ម បសុសត្វ ព្រៃឈើ បរិស្ថាន និងជលផល | √ | | √ | √ | √ |
| អាជ្ញាធរមូលដ្ឋាន (ខេត្ត ស្រុក ឃុំ ភូមិ) | √ | | √ | √ | √ |
| ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត | | √ | | | |
| សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវពាក់ព័ន្ធ | √ | √ | √ | √ | √ |
| កសិករ សហគមន៍កសិករ | √ | | √ | √ | |
| អង្គការសង្គមស៊ីវិល | √ | | √ | √ | |
| វិស័យឯកជន | √ | √ | √ | √ | √ |
| អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ | √ | √ | √ | √ | |
| ក្រុមតាមវិស័យ (ឧ. ក្រុមស្ត្រី ក្រុមយុវជន ជនជាតិដើម) | √ | √ | √ | √ | |

## ៨. កម្រងការកសាងសមត្ថភាព (គ្រប់កម្រិត - ជាតិ មូលដ្ឋាន និងកសិករ)

គោលការណ៍ណែនាំនេះ ផ្តោតលើអ្នកពាក់ព័ន្ធផ្នែកកសិកម្មគ្រប់កម្រិតចាប់ពីអ្នកធ្វើសេចក្តីសម្រេចចិត្ត/អ្នកធ្វើគោលនយោបាយ អាជ្ញាធរមូលដ្ឋាន អ្នកធ្វើផែនការ ដៃគូអភិវឌ្ឍន៍ វិស័យឯកជនរហូតដល់កសិករ។ ការលើកកម្ពស់សមត្ថភាពរបស់អ្នកពាក់ព័ន្ធសំខាន់ៗនៅកម្រិតផ្សេងៗគ្នារួមមាន ការធ្វើផែនការ ការផ្សព្វផ្សាយ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ CSA។ ការកសាងសមត្ថភាពលើអ្នកពាក់ព័ន្ធ ត្រូវផ្តោតសំខាន់លើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- តួនាទីរបស់អ្នកពាក់ព័ន្ធនៅកម្រិតផ្សេងៗគ្នា
- វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី របស់សហគមន៍មូលដ្ឋាន ជនជាតិដើម
- កម្រិតចំណេះដឹង និងវ័យ
- ទីផ្សាផលិតផលកសិកម្ម
- លក្ខខណ្ឌរូបសាស្ត្រ (គុណភាពដី ជម្រាល ប្រភពទឹក ធនធានហិរញ្ញវត្ថុ និងធនធានរូបវន្តផ្សេងៗ)។

### ក. ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ការផ្តល់ការបណ្តុះបណ្តាលរយៈពេលខ្លី និងរយៈពេលវែងដល់មន្ត្រីជំនាញ មន្ត្រី/ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម និងអ្នកពាក់ព័ន្ធផ្សេងៗ លើបច្ចេកទេស CSA មានសារៈសំខាន់ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការរចនាគោលនយោបាយ និងរៀបចំផែនការ ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ ការបន្សាំនិងការប្រែប្រួលអាកាសធាតុ និងការអនុវត្ត CSA។ ការបណ្តុះបណ្តាលគួរផ្តោសំខាន់លើ៖

- ជំនាញសម្របសម្រួលទីផ្សារ
- បច្ចេកទេស CSA តាមលក្ខខណ្ឌផ្សេងគ្នានៃក្សេត្របរិស្ថាន
- បច្ចេកទេសជ្រើសរើសពូជ ដាំដុះ ថែទាំ ប្រមូលផល ទៅតាមប្រភេទដី និងទីផ្សារ
- ការអនុវត្តប្រព័ន្ធកសិកម្មច្រុះ
- បច្ចេកទេសស្រោចស្រព ការប្រើប្រាស់ទឹក ការគ្រប់គ្រងទឹក
- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងវិធីសាស្ត្របន្សាំ
- ទិន្នន័យអាកាសធាតុ ឬសេវាកម្មព័ត៌មានផ្សេងៗ
- ចំណេះដឹងលើ M&E របស់ CSA។

### ខ. កម្រិតមូលដ្ឋាន (ស្រុក ឃុំ/សង្កាត់ ភូមិ)

អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មកម្រិតមូលដ្ឋាន គួរផ្តល់ការបណ្តុះបណ្តាលបន្ថែម ដោយគ្រូបណ្តុះបណ្តាលបង្គោល ដែលអាចជាមន្ត្រីជំនាញ មន្ត្រី/ភ្នាក់ងារផ្សព្វផ្សាយកសិកម្មថ្នាក់ជាតិ អ្នកជំនាញ ទីភ្នាក់ងារអភិវឌ្ឍន៍ (រួមទាំងអង្គការក្រៅរដ្ឋាភិបាល) សាកលវិទ្យាល័យ ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេពាក់ព័ន្ធនឹងបច្ចេកវិទ្យា CSA ដើម្បីអាចឱ្យពួកគេមានសមត្ថភាពបណ្តុះបណ្តាលកសិករបន្ត អាចរៀបចំនិងដឹកនាំកម្មសិក្សាកសិករ (ឧ. ដំណើរទស្សនកិច្ចសិក្សារបស់កសិករ) ជាដើម។ បន្ទាប់ពីបណ្តុះបណ្តាល ភ្នាក់ងារផ្សព្វផ្សាយកសិកម្មកម្រិតមូលដ្ឋាន អាចមានជំនាញបច្ចេកទេស សមសម្របសម្រួល និងលើកកម្ពស់ទំនាក់ទំនង

រវាងសហគមន៍ ឬកសិករ និងស្ថាប័នសាធារណៈ ឬឯកជន។ ការបណ្តុះបណ្តាលគួរផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម៖

- ជំនាញសម្របសម្រួល ទីផ្សា ទស្សនកិច្ចសិក្សា
- ការរៀបចំផែនការ គម្រោងថវិកា សេដ្ឋកិច្ច
- បច្ចេកទេស CSA តាមលក្ខខណ្ឌប្រភេទដីផ្សេងគ្នា
- បច្ចេកទេសជ្រើសរើសពូជ ដាំដុះ ថែទាំ ប្រមូលផល និងប្រព័ន្ធកសិកម្មច្រុះ
- បច្ចេកទេសស្រោចស្រព ការប្រើប្រាស់ទឹក ការគ្រប់គ្រងទឹក
- ចំណេះដឹងលើ M&E លើការអនុវត្ត CSA។

### គ. កម្រិតកសិដ្ឋាន

សម្រាប់កម្រិតមូលដ្ឋាន សហគមន៍ និងកសិករ ការបណ្តុះបណ្តាលកសិករនៅទីវាល សិក្ខាសាលាតាមភូមិ និងទស្សនកិច្ចសិក្សានៅទីតាំងអនុវត្ត CSA ជោគជ័យ គឺមានប្រសិទ្ធភាពបំផុត ដើម្បីផ្តល់ចំណេះដឹង បង្កើនការយល់ដឹង និងពង្រឹងសមត្ថភាពរបស់កសិករ និងសហគមន៍ ក្នុងការលើកកម្ពស់ការអនុវត្ត CSA នៅក្នុងប្រទេស។ ការបណ្តុះបណ្តាលគួរផ្តោតសំខាន់លើប្រធានបទដូចខាងក្រោម៖

- ការរៀបចំផែនការកសិដ្ឋាន ដាំដុះទៅតាមតម្រូវការទីផ្សា
- បច្ចេកទេស CSA តាមលក្ខខណ្ឌប្រភេទដីផ្សេងគ្នា
- បច្ចេកទេសជ្រើសរើសពូជ ដាំដុះ ថែទាំ ប្រមូលផល
- បច្ចេកទេសស្រោចស្រព ការប្រើប្រាស់ទឹក ការគ្រប់គ្រងទឹក
- បច្ចេកទេសថែទាំប្រព័ន្ធស្រោចស្រព និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តកសិដ្ឋាន។ល។

# ឯកសារយោង


ASEAN. (2016). ASEAN Guidelines on the Promotion of Climate Smart Agriculture (CSA) Practices. ASEAN – Agriculture- Climate Resilience Guidelines - Agriculture- Regional Cooperation. ISBN 978-602-0980-86-7Jakarta, ASEAN Secretariat, March 2016

FAO. (2018). Climate Smart Agriculture – Ministry of Agriculture, Livestock and Fisheries Training Manual for Extension Agents in Kenya. ISBN 978-92-5-130780-9

Labios RV, Galang EIN, Orencio PM, Malayang DBN, Vallez AGC, and Lapitan RB. (2021). ASEAN Regional Guidelines for Promoting Climate-Smart Agriculture (CSA) Practices Vol. 3. Association of Southeast Asian Nations - Climate Resilience Network (ASEAN - CRN). 40p. Jakarta, ASEAN Secretariat, Indonesia

Ministry of Agriculture Livestock and Fisheries. (2017). Climate – Smart Agriculture Guideline. Ministry of Agriculture Livestock and Fisheries. The United Republic of Tanzania

SNV. (2024). Climate-Smart Agriculture - Cambodia. Recollit de https://www.snv.org/project/climate-smart-agriculture-cambodia

World Bank. (2024). Climate Smart Agriculture. Recollit de World Bank Group: https://www.worldbank.org/en/topic/climate-smart-agriculture